**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចសន្ទនា
## កិច្ចសហប្រតិបត្តិការអាស៊ីលើកទី១៧

ថ្ងៃទី២១ ខែមករា ឆ្នាំ ២០២១ តាមប្រព័ន្ធវីដេអូ

-------------

នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចសន្ទនាកិច្ចសហប្រតិបត្តិការអាស៊ី លើកទី១៧ (17th Ministerial Meeting of the Asia Cooperation Dialogue – ACD) ដែលមានឯកឧត្តម ម៉េវលុត ឆាវូស៊ូលុ រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋតួកគី ជាប្រធាននៃកិច្ចប្រជុំ។ កិច្ចប្រជុំនេះ សម្រេចបាននូវលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

ក្រោមមូលបទ «ទេសចរណ៍តាមគន្លងថ្មី មានសុវត្ថិភាព និងសុខភាពល្អ» (The New Normal and Safe and Healthy Tourism) ប្រទេសជាសមាជិក ACD បានទទួលស្គាល់នូវភាពចាំបាច់បន្ទាន់ក្នុងការដោះស្រាយបញ្ហាប្រឈមនានាបណ្តាលមកពីជំងឺរាតត្បាតកូវីដ-១៩ និងបានឯកភាពរួមគ្នាដោះស្រាយផលប៉ះពាល់លើបញ្ហាសង្គម-សេដ្ឋកិច្ច រួមទាំងវិស័យទេសចរណ៍ តាមរយៈអភិក្រមពហុវិស័យ។ កិច្ចសហការរួមគ្នានេះ រួមបញ្ចូលទាំងវិធានការចាំបាច់ទាំងអស់ក្នុងការការពារសុខភាព និងសុវត្ថិភាព ការពង្រឹងកិច្ចសហប្រតិបត្តិការនិងការគាំទ្រគ្នាទៅវិញទៅមក ការរួមកម្លាំងក្នុងកិច្ចខិតខំប្រឹងប្រែងស្តារនិងអភិវឌ្ឍទេសចរណ៍ជាតិឡើងវិញ ការចែករំលែកចំណេះដឹងនិងឧត្តមានុវត្តន៍ ក៏ដូចជាការជំរុញលំហូរវិនិយោគ និងពាណិជ្ជកម្មក្នុងតំបន់ក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យប្រសើរឡើងនូវសន្តិសុខផ្នែកសុខាភិបាល និងការស្តារឡើងវិញប្រកបដោយចីរភាព។

នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន បានចែករំលែកអង្គប្រជុំនូវការប្តេជ្ញាចិត្តដ៏រឹងមាំរបស់កម្ពុជា ក្នុងការដាក់ចេញនូវផែនការចាក់វ៉ាក់សាំងថ្នាក់ជាតិជូនប្រជាជនប្រកបដោយប្រសិទ្ធភាព និងផែនការស្តារឡើងវិញវិស័យទេសចរណ៍គ្រប់ជ្រុងជ្រោយ ដែលមិនត្រឹមតែជានាំនូវការស្តារប្រកបដោយសុវត្ថិភាព និងឆាប់រហ័ស នៃក្បាលម៉ាស៊ីនជំរុញកំណើនដ៏សំខាន់សម្រាប់ជាតិនោះទេ ថែមទាំងរួមចំណែកយ៉ាងសកម្ម និងប្រកបដោយការទទួលខុសត្រូវដល់ការស្តារវិស័យទេសចរណ៍ និងវិស័យផ្សេងទៀត ក្នុងតំបន់ទាំងមូល។



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ជាងនេះទៅទៀត **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់សារជាថ្មីនូវការប្តេជ្ញាចិត្តរបស់ប្រទេសសមាជិកទាំងអស់ ដើម្បីបន្តឱ្យ ACD ឈានទៅជាវេទិកាពហុភាគីដ៏សំខាន់ក្នុងការលើកកម្ពស់កិច្ចសន្ទនា និងការពឹងផ្អែកគ្នាទៅវិញទៅមកនៅគ្រប់វិស័យនៃកិច្ចសហប្រតិបត្តិការ។

រដ្ឋមន្ត្រីការបរទេស និងតំណាងជាន់ខ្ពស់របស់ ACD ក៏បានសម្តែងនូវការកោតសរសើរដល់ប្រទេសតួកគី ក្នុងតួនាទីជាប្រធានប្រកបដោយជោគជ័យសម្រាប់អាណត្តិ ២០១៩-២០២០ និងការបន្តធ្វើជាប្រធានរហូតដល់ខែកញ្ញា ឆ្នាំ ២០២១។

អង្គប្រជុំបានបិទបញ្ចប់ដោយការអនុម័តសេចក្តីថ្លែងការណ៍ទីក្រុងអង់ការ៉ានៃរដ្ឋមន្ត្រីការបរទេស ACD ។

ថ្ងៃសុក្រ ៩កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ២០២១

KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION

PRESS RELEASE

Outcomes of the 17th Ministerial Meeting of the Asia Cooperation Dialogue-ACD

21st January 2021, Video Conference

------------------

On 21st January 2021, His Excellency PRAK Sokhonn, Deputy Prime Minister, Minister of Foreign Affairs and International Cooperation of the Kingdom of Cambodia, participated in the 17th Ministerial Meeting of the Asia Cooperation Dialogue - ACD, which was chaired by His Excellency Mevlüt Çavuşoğlu, Minister of Foreign Affairs of the Republic of Turkey. The key outcomes of the meeting are as follows:

Under the theme "The New Normal and Safe and Healthy Tourism", ACD Member States recognized the urgent necessity in addressing the challenges brought about by the COVID-19 pandemic and agreed to collectively address its adverse socio-economic impacts including the tourism sector through a multifaceted approach. The joint collaboration encompasses, among others, all necessary precautionary health and safety measures, the enhancement of cooperation and mutual support, the synergizing of national tourism recovery and development efforts, the sharing of best practices and knowledge, as well as the promotion of intra-regional trade and investment flows in the effort to enhance health security and sustain recovery.

During the Meeting, His Excellency Deputy Prime Minister PRAK Sokhonn shared with the meeting Cambodia's steadfast commitment to roll out an effective national vaccination plan for her people and the country's comprehensive tourism recovery plan which purports to not only ensure a safe and speedy recovery of this important growth



Address : N° 3, Samdech HUN Sen Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia

Tel : (855) 23 216 122
Fax : (855) 23 216 141, 023 213 341
Email : mfaic@mfaic.gov.kh

engine of the Kingdom but also to responsibly and actively contribute to the recovery of tourism and other sectors in the whole region.

Furthermore, **His Excellency Deputy Prime Minister PRAK Sokhonn** reaffirmed the shared commitment of all Member States to continue advancing the ACD as a key multilateral platform to promote dialogue and interdependence in all areas of cooperation.

ACD Foreign Ministers and High Representatives also expressed appreciation to Turkey for her successful chairmanship over the term 2019-2020 and for offering to extend the chairmanship until September 2021.

The Meeting concluded by adopting the Ankara Declaration of the ACD Ministers.

Phnom Penh, 22 January 2021